ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ ១៣៧២...ឧស.ឋ.ល...កសក

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារ
## ក្នុងក្របខណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឆ្នាំ ២០១៦

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត និងសាធារណៈជនឱ្យបានជ្រាបថា៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្មនឹងធ្វើការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងសម្រាប់ឆ្នាំ២០១៦នេះចំនួន១៦៨ កន្លែង ដើម្បីបំពេញការងារនៅតាមទីស្តីការក្រសួង និងមន្ទីររាជធានី-ខេត្ត ដូចខាងក្រោម៖

**១- លក្ខខណ្ឌជ្រើសរើស ៖**

១.១. បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ជាតិខ្មែរ ហើយត្រូវមានអាយុស្របទៅតាមការកំណត់ដូចមានចែងខាងក្រោម៖

ក- ចំពោះបេក្ខជនជាសិស្ស និស្សិត ដែលដាក់ពាក្យស្នើសុំចុះឈ្មោះប្រឡងចូលក្របខណ្ឌប្រភេទ **ក** ត្រូវមានអាយុច្រើនបំផុតត្រឹម ៣០ឆ្នាំ (ឬច្រើនបំផុតកើតក្នុងឆ្នាំ ១៩៨៦) ។

ខ- ចំពោះបេក្ខជនជាសិស្ស និស្សិត ដែលដាក់ពាក្យស្នើសុំចុះឈ្មោះប្រឡងចូលក្របខណ្ឌប្រភេទ **ខ** ត្រូវមានអាយុច្រើនបំផុតត្រឹម ២៨ឆ្នាំ (ឬច្រើនបំផុតកើតក្នុងឆ្នាំ ១៩៨៨) ។

១.២. បេក្ខជនក្របខណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រទាបបំផុតសមមូលកម្រិតបរិញ្ញាប័ត្រ។ ចំពោះបេក្ខជនក្របខណ្ឌប្រភេទ **ខ** ត្រូវមានសញ្ញាបត្រទាបបំផុតសមមូលកម្រិតមធ្យមសិក្សាប័ត្រភាគទី ២+ ២ ឆ្នាំសិក្សា ក្នុងគ្រឹះស្ថានឧត្តមសិក្សា (បរិញ្ញាបត្ររង)។ បេក្ខជនទាំងអស់ ត្រូវមានចំណេះដឹងជាបឋមលើជំនាញកុំព្យូទ័រ (Microsoft Word & Excel) ដែលមានវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ។

១.៣. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ។

១.៤. បេក្ខជនដែលដាក់ពាក្យសុំប្រឡងប្រជែងចូលបម្រើការងារនៅទីស្តីការក្រសួង ក៏ដូចជានៅតាមមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ត្រូវមានលំនៅឋានអចិន្ត្រៃយ៍នៅរាជធានី-ខេត្តដែលខ្លួនបានចុះឈ្មោះប្រឡង។

១.៥. ការផ្តល់អាទិភាព និងលើកទឹកចិត្ត៖

១. ចំពោះបេក្ខជនជានារី ជនពិការ ដែលមានសមត្ថភាពសមស្របអាចបម្រើការងារបាន។

២. បេក្ខជននៅតំបន់ដាច់ស្រយាល ត្រូវបានលើកទឹកចិត្តសម្រាប់ការប្រឡង។

៣. បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យា ដែលបានបម្រើការងារនៅតាមអង្គភាពនីមួយៗ ក្រោមឱវាទក្រសួង

៤. ចំពោះបេក្ខជន ដែលមានកម្រិតជំនាញបច្ចេកទេស ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ក្រសួង អាចនឹងទទួលបានការលើកទឹកចិត្តផងដែរ។



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

## ២- មុខជំនាញជ្រើសរើស ៖

១.១. ក្របខណ្ឌ **ក** ចំនួន ១២៤ កន្លែង លើមុខជំនាញដូចខាងក្រោម៖

- គីមីវិទ្យា
- ទេពកោសល្យគីមីចំណីអាហារ
- បច្ចេកទេសយន្តសាស្ត្រ
- សំណង់ស៊ីវិល
- អគ្គិសនី និងអេឡិចត្រូនិច
- ឧស្សាហកម្ម មេកានិច
- ព័ត៌មានវិទ្យា
- រដ្ឋបាលសាធារណៈ
- នីតិសាស្ត្រ និងសេដ្ឋកិច្ច
- ទំនាក់ទំនងអន្តរជាតិ
- គណនេយ្យ និងគ្រប់គ្រង
- ហិរញ្ញវត្ថុ និងធនាគារ
- ភាសាអង់គ្លេស

១.២. ក្របខ័ណ្ឌ **ខ** ចំនួន ៤៤ កន្លែង លើមុខជំនាញដូចខាងក្រោម៖

- រដ្ឋបាលសាធារណៈ ឬរដ្ឋបាលទូទៅ
- នីតិសាស្ត្រ និងសេដ្ឋកិច្ច
- គណនេយ្យ និងគ្រប់គ្រង
- ហិរញ្ញវត្ថុ និងធនាគារ
- ព័ត៌មានវិទ្យា

## ៣- ការបែងចែកឱ្យទៅបម្រើការងារ ៖

៣.១ សម្រាប់បម្រើការងារនៅទីស្ដីការក្រសួង (ក្របខណ្ឌ **ក** ចំនួន ៦១កន្លែង និងក្របខណ្ឌ **ខ** ចំនួន ០៧កន្លែង) សរុបចំនួន ៦៨ កន្លែង

៣.២ សម្រាប់បម្រើការងារនៅតាមមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត ចំនួន ១០០ កន្លែង (ក្នុងមួយមន្ទីរ ចំនួន ៤កន្លែង)

| អង្គភាព | ចំនួនកន្លែងជ្រើសរើស | ប្រភេទក្របខណ្ឌ | | អង្គភាព | ចំនួនកន្លែងជ្រើសរើស | ប្រភេទក្របខណ្ឌ | |
|---|---|---|---|---|---|---|---|
| | | ក | ខ | | | ក | ខ |
| ១.រាជធានីភ្នំពេញ | ៤ | ២ | ២ | ១៤.ត្បូងឃ្មុំ | ៤ | ២ | ២ |
| ២.កណ្ដាល | ៤ | ២ | ២ | ១៥.កំពង់ចាម | ៤ | ២ | ២ |
| ៣.ព្រះសីហនុ | ៤ | ៤ | ០ | ១៦.ស្ទឹងត្រែង | ៤ | ២ | ២ |
| ៤.កោះកុង | ៤ | ៤ | ០ | ១៧.កំពង់ស្ពឺ | ៤ | ២ | ២ |
| ៥.កំពង់ឆ្នាំង | ៤ | ៤ | ០ | ១៨.កំពត | ៤ | ៣ | ១ |
| ៦.កំពង់ធំ | ៤ | ២ | ២ | ១៩.កែប | ៤ | ២ | ២ |
| ៧.បាត់ដំបង | ៤ | ២ | ២ | ២០.តាកែវ | ៤ | ៤ | ០ |
| ៨.ប៉ៃលិន | ៤ | ២ | ២ | ២១.បន្ទាយមានជ័យ | ៤ | ២ | ២ |
| ៩.ព្រៃវែង | ៤ | ៤ | ០ | ២២.ឧត្តរមានជ័យ | ៤ | ២ | ២ |
| ១០.ស្វាយរៀង | ៤ | ២ | ២ | ២៣.រតនៈគិរី | ៤ | ២ | ២ |
| ១១.ពោធិ៍សាត់ | ៤ | ៤ | ០ | ២៤.មណ្ឌលគិរី | ៤ | ២ | ២ |
| ១២.សៀមរាប | ៤ | ២ | ២ | ២៥.ព្រះវិហារ | ៤ | ២ | ២ |
| ១៣.ក្រចេះ | ៤ | ៤ | ០ | សរុប | ១០០ | ៦៣ | ៣៧ |

### ៤- កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យសុំប្រឡង ៖

- កាលបរិច្ឆេទទទួលពាក្យ ៖ ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រៀងរាល់ពេលម៉ោងធ្វើការ។
  + ពេលព្រឹកចាប់ពីម៉ោង ៖ ៧: ៣០-១១:៣០នាទី
  + ពេលរសៀលចាប់ពីម៉ោង ៖ ១៤:៣០-១៧:០០នាទី
- កាលបរិច្ឆេទឈប់ទទួលពាក្យ ៖ ថ្ងៃ សុក្រ ទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ត្រឹមវេលាម៉ោង ១៧: ០០នាទី ជាកាលបរិច្ឆេទចុងក្រោយ។
- ទីកន្លែងទំនាក់ទំនង និងទទួលពាក្យ ៖
  - ចំពោះបេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលបម្រើការងារនៅថ្នាក់រដ្ឋបាលកណ្តាល (ទីស្តីការក្រសួង) ត្រូវដាក់ពាក្យនៅលេខាធិការដ្ឋាននៃគណៈកម្មការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួង( នាយកដ្ឋានបុគ្គលិក)។
  - ចំពោះបេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលបម្រើការងារនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត ត្រូវដាក់ពាក្យនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត ក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់ដោយប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត។

### ៥- សំណុំលិខិតសុំចុះឈ្មោះប្រឡង ៖

| | |
|---|---|
| ១- ពាក្យសុំចុះឈ្មោះប្រឡង (មានគំរូស្រាប់) | ចំនួន ០១ ច្បាប់ |
| ២- ជីវប្រវត្តិសង្ខេបមានបិទរូបថត ( ៤ គុណ ៦ ) (មានគំរូស្រាប់) | ចំនួន ០១ ច្បាប់ |
| ៣- សលាកបត្រឯកត្តជន (មានគំរូស្រាប់) | ចំនួន ០២ ច្បាប់ |
| ៤- រូបថតថ្មី ៤ គុណ ៦ (ថតចំពីមុខ) | ចំនួន០២ សន្លឹក |
| ៥- បង្កាន់ដៃទទួលពាក្យ (មានគំរូស្រាប់) | ចំនួន០២ ច្បាប់ |
| ៦- កិច្ចសន្យា (មានគំរូស្រាប់) | ចំនួន ០១ ច្បាប់ |
| ៧- ច្បាប់ចម្លងប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ចំនួន ០១ ច្បាប់ |
| ៨- លិខិតថ្កោលទោស ( ក្រោយពេលប្រឡងជាប់ ) | ចំនួន ០១ ច្បាប់ |
| ៩- លិខិតពិនិត្យសុខភាព ( ក្រោយពេលប្រឡងជាប់ ) | ចំនួន០១ ច្បាប់ |
| ១០- លិខិតបញ្ជាក់ពិការភាព (ចំពោះជនពិការ) | ចំនួន ០១ ច្បាប់ |
| ១១- សេចក្តីចម្លងសញ្ញាប័ត្រ ឬលិខិតបញ្ជាក់ការសិក្សាដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ ច្បាប់ |

### ៦- វិញ្ញាសាប្រឡង ៖

*សម្រាប់ការប្រឡងចូលប្រភេទក្របខណ្ឌ « ក »*

១- វិញ្ញាសាវប្បធម៌ទូទៅ *រយៈពេល ២ ម៉ោង*

២- វិញ្ញាសាភាសាអង់គ្លេសទូទៅ *រយៈពេល ១ ម៉ោង និង ៣០ នាទី*

៣- វិញ្ញាសាជំនាញបច្ចេកទេស ដែលទាក់ទងនឹងមុខជំនាញដែលបេក្ខជនស្នើសុំចុះឈ្មោះប្រឡង ដូចបានបញ្ជាក់ខាងលើ *រយៈពេល ២ ម៉ោង*

*សម្រាប់ការប្រឡងចូលប្រភេទក្របខណ្ឌ « ខ »*

១- វិញ្ញាសាវប្បធម៌ទូទៅ *រយៈពេល ២ ម៉ោង*

២- វិញ្ញាសាភាសាអង់គ្លេសទូទៅ *រយៈពេល ១ ម៉ោង និង ៣០ នាទី*



K ⁴
ξ 2

**៧- កាលបរិច្ឆេទ និងមណ្ឌលប្រឡង ៖**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងជូនដំណឹងពេលក្រោយយ៉ាងយូរឲ្យបានមុនរយៈពេល ១ សប្តាហ៍ នៃកាលបរិច្ឆេទប្រឡង។ សូម បេក្ខជន តាមដានព័ត៌មាននៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម តាមអាសយដ្ឋានទំនាក់ទំនងដូចបានបញ្ជាក់ជូនខាងក្រោម។

**សេចក្តីបញ្ជាក់៖**

- បេក្ខជន ត្រូវសរសេរ និងបំពេញសំណុំលិខិតសុំចុះឈ្មោះប្រឡង ត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែងចូលបម្រើការងារដោយខ្លួនឯងផ្ទាល់
- បេក្ខជន ត្រូវទៅធ្វើលិខិតបញ្ជាក់ពីសុខភាពនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងលិខិតថ្កោលទោសនៅក្រសួងយុត្តិធម៌ ជាបន្ទាន់ក្រោយពីការប្រឡងជាប់
- ករណីគេឃើញអ្នកប្រឡងជំនួស បេក្ខជននឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ អ្នកមកប្រឡងជំនួស នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។
- ព័ត៌មានលម្អិត សូមមកទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិក (ការិយាល័យបៀវត្ស) និងនៅតាមមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត រៀងរាល់ម៉ោងធ្វើការ ឬចូលទៅកាន់គេហទំព័រ www.mih.gov.kh និង Facebook នាយកដ្ឋានបុគ្គលិក ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

អាស្រ័យហេតុនេះ សូមសិស្ស-និស្សិត និងសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**គឹម ទូច**

**កន្លែងទទួល ៖**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងមុខងារសាធារណៈ

-គ្រប់ក្រសួង-ស្ថាប័ន *"ដើម្បីជូនជ្រាប"*

-គ្រប់អង្គភាពចំណុះក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-គ្រឹះស្ថានសិក្សា

*"ដើម្បីជួយផ្សព្វផ្សាយ"*

- ឯកសារ-កាលប្បវត្តិ